CITY OF
LONGBEACH

# សេចក្តីប្រកាសព័ត៌មាន

**៤/១៧/២០២០**

**សម្រាប់ការចេញផ្សាយភ្លាមៗ** សេចក្តីប្រកាសព័តិមាន #០៤១៧២០

**ប្រធានបទ:** **ទីក្រុងឡុងប៊ិច ធ្វើសចក្តីប្រកាស អំពីទីតាំងថ្មី ចំនួនបីកន្លែង សម្រាប់ធ្វើតេស្ត កូវិដ-១៩ COVID-19 នៅទីក្រុងឡុងប៊ិច**

**ទំនាក់ទំនង:** ទីក្រុងឡុងប៊ិច ចូលរួមជាមួយមជ្ឈមណ្ឌលព័តិមាន
562.570.NEWS (ការសាកសួរព័តិមាន តែប៉ុណ្ណោះ)
jic@longbeach.gov (ការសាកសួរព័តិមាន តែប៉ុណ្ណោះ)
ប្រជាជន: សូមទូរស័ព្ទ 562.570.INFO

ក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា - ចាប់ផ្តើមពីថ្ងៃសៅរ៍ ទី១៨ ខែមេសា នឹងមានទីតាំងថ្មី ចំនួនបីកន្លែង នៅទីក្រុងឡុងប៊ិច ដែលបច្ចុប្បន្ននេះ មានសម្ថភាពលើសបីដង ក្នុងការធ្វើតេស្តនៅក្រុងឡុងប៊ិច។

" ការពង្រីកទីតាំងធ្វើតេស្ត គឺមានសារៈសំខាន់ណាស់ ហើយទីតាំងថ្មីទាំងបីនេះ រួមជាមួយកន្លែង មហាវិទ្យាល័យឡុងប៊ិចស៊ីធីខឡិចរបស់យើង អាចជួយយើងធ្វើតេស្តមនុស្សចំនួនជាង ៥០០នាក់ ក្នុងមួយថ្ងៃ" នេះជាប្រសាន៍របស់លោកអភិបាលក្រុង រូបើដ កាស្យា Mayor Robert Garcia។ " យើងមិន រងចាំប្រដាប់ធ្វើតេស្ត នឹងមកដល់បន្ថែមទៀតនោះទេ ក៏ប៉ុន្តែ យើងកំពុងតែទិញរបស់ទាំងនោះ យ៉ាងសកម្ម សម្រាប់មើលថែរក្សា ទីក្រុងរបស់យើង។"

ក្រុងឡុងប៊ិច នឹងចាប់ផ្តើមប្រតិបត្តិការបើករថយន្តចូលធ្វើតេស្ត កូវិដ-១៩ COVID-19 ដោយមិនគិតថ្លៃ មាននៅទីតាំងថ្មីពីរ ថែមទៀត នៅឯ ភូមិភាគជើង និងខាងលិចឡុងប៊ិច ព្រមទាំងមានបន្ថែមទៀតការធ្វើតេស្តនៅ ក្លីនិកពិនិត្យរហ័ស Rapid Assessment Clinic នាពេលបច្ចុប្បន្ននេះ កំពុងគ្រប់គ្រងដោយនាយកដ្ឋាន សុខភាព និងសេវាកម្មមនុស្ស ដែលមានទីតាំងនៅមហាវិទ្យាល័យឡុងប៊ិចស៊ីធីខឡិច លើផ្លូវប៉ាស៊ីហ្វិកកូស (PCC)។ បន្ថែមទៀត មានកន្លែងថ្មី សម្រាប់បើករថយន្ត ចូលទៅធ្វើតេស្ត ដែលមានផ្តល់ជូននៅឯមន្ទីរពេទ្យសាំម៉ារី។ ហើយទីតាំងទាំងអស់នេះ បើកជា សាធារណៈ តាមរយះការដាក់ថ្ងៃណាត់ជួបពិនិត្យ តែប៉ុណ្ណោះ។

ទីតាំងថ្មីសម្រាប់ធ្វើតេស្តនៅទីក្រុង និងមានដំណើការប្រាំពីរថ្ងៃ ក្នុងមួយអាទិត្យ ចាប់ពីម៉ោង ១០ ព្រឹក ទៅម៉ោង ១ រសៀល រហូតដល់មានការជូនដំណឹងបន្ថែមទៀត ហើយអាចមានទីតាំងផ្សេងៗទៀត នៅខាងក្រោមនេះ :

- **Jordan High School, 6500 Atlantic Ave. សាលាវិទ្យាល័យជូដិន (ច្រកចូលតាមផ្លូវអាត្លង់ទិក)**
- **Cabrillo High School, 2001 Santa Fe Ave. សាលាវិទ្យាល័យកាប្រីឡូ (ច្រកចូលតាមផ្លូវ Santa Fe Avenue លើផ្លូវ W. Willard Street)**

ការធ្វើតេស្តនេះ គឺមាននៅទីតាំងទាំងពីរ តាមការដាក់ថ្ងៃណាត់ជួបតែប៉ុណ្ណោះ។ ការណាត់ជួបក្នុងថ្ងៃតែមួយ ឬនៅថ្ងៃបន្ទាប់ នឹងបើកសម្រាប់អ្នកទាំងអស់ ដែលមានរោគសញ្ញា។ ខណៈពេលធ្វើតេស្ត មានសារៈសំខាន់ សម្រាប់ផ្តល់ជូនបុគ្គលអាយុលើសពី ៦៥ឆ្នាំ ឬអ្នកមានជំងឺសុខភាពរ៉ាំរ៉ៃ ព្រមទាំងអ្នកមានរោគសញ្ញាកូវិដ-១៩ COVID-19។ បុគ្គលណា ដែលមានចំណាប់អារម្មណ៍ គួរតែចូលមើលក្នុងបណ្តាញគេហទំព័រ របស់ទីក្រុង City's [COVID-19 testing page] អំពីការធ្វើតេស្ត និងឆ្លើយសំណួរមុនពេលទៅពិនិត្យ។ ចំពោះប្រជាជនណា ដែលមិនមានអាស័យដ្ឋានអ៊ីម៉ែល ឬអ្នកត្រូវការជំនួយដាក់ការណាត់ជួប អាចទាក់ទងទៅទីក្រុងផ្នែកព័ត៌មាន កូវិដ-១៩ តាមទូរស័ព្ទទាន់ហេតុការណ៍ (562) 570-INFO (4636) ។

ការធ្វើតេស្តនេះ គឺមាននៅទីតាំងថ្មីរបស់ទីក្រុង ដែលនឹងធ្វើតេស្តតាមរយះប្រដាប់ជូតទៅក្នុងមាត់ ដោយមិនបាច់ត្រូវការជំនួយនោះទេ។ ទីក្រុងរំពឹងថា នឹងធ្វើតេស្តមនុស្សប្រមាណ ១២0នាក់ ក្នុងមួយថ្ងៃ នៅតាមទីតាំងថ្មី និមួយៗ។

បុគ្គលដែលមានលទ្ធផលតេស្តវិជ្ជមានផ្ទុកមេរោគនេះ នឹងត្រូវជូនដំណឹងប្រាប់តាមរយៈអ៊ីម៉ែល ហើយអ្នកស៊ើបអង្កេតករណីរបស់មន្ទីរសុខាភិបាល នៃទីក្រុងឡុងប៊ិច នឹងទាក់ទងតាមទូរស័ព្ទ។ ចំពោះបុគ្គលដែលមានលទ្ធផលតេស្តអវិជ្ជមានផ្ទុកមេរោគនេះ នឹងត្រូវជូនដំណឹងប្រាប់តាមរយះអ៊ីម៉ែល។

បន្ថែមទៀត ទីតាំធ្វើតេស្តនៅមន្ទីរពេទ្យសាំងម៉ារី មានទីតាំងនៅផ្លូវ 1050 Linden Ave. ហើយរំពឹងថា នឹងធ្វើតេស្តមនុស្សប្រមាណ ២00នាក់ ក្នុងមួយថ្ងៃ នៅទីតាំងនេះ នឹងត្រូវបើកចាប់ពីថ្ងៃចន្ទ័ រហូតដល់ថ្ងៃសុក្រ ចាប់ពីម៉ោង ៨ព្រឹក ទៅដល់ថ្ងៃត្រង់ និងពីម៉ោង ១រសៀល ទៅដល់ម៉ោង ៤ រសៀល។

ទិន្នន័យថ្មីៗ ពីទីក្រុងឡុងប៊ិចនេះ បានបង្ហាញអំពីភាពខុសគ្នា ក្នុងករណីវិជ្ជមានផ្ទុកមេរោគ ដែលបានព្យាបាលនៅមន្ទីរពេទ្យ កំពុងតែបះពាល់ទៅដល់សហគមន៍ជនជាតិអាហ្វ្រិអាមេរិកាំង ដែលស្រដៀងគ្នាទៅនឹងទិន្នាការជាតិផងដែរ។ ទីក្រុងឡុងប៊ិចបានប្តេជ្ញាចិត្តធានាថា ប្រជាជនទាំងអស់ត្រូវទទួលបានការអប់រំអំពី កូវិដ-១៩ COVID-19 និងមានសិទ្ធិចាំបាច់ក្នុងការទទួលធ្វើតេស្ត កូវិដ-១៩ COVID-19 ប្រសិនបើពួកគេមានរោគសញ្ញានេះ។ តាមរយៈការបង្កើតបន្ថែមទីតាំងធ្វើតេស្ត ទូទាំងក្រុងឡុងប៊ិច ហើយទីក្រុងនឹងព្យាយាមផ្តល់ឱកាសបន្ថែមទៀត សម្រាប់ប្រជាជនទាំងអស់ ប្រសិនបើលទ្ធផលតេស្តរបស់ពួកគេវិជ្ជមានផ្ទុកមេរោគនេះ នឹងទទួលបានការគាំទ្រ ក្នុងខណៈពេលនៅឯកាម្នាក់ឯង និងទទួលការព្យាបាលយ៉ាងឿនរហ័ស បើសិនមានការចាំបាច់ ដើម្បីការពារដល់ផលពិបាក បន្ថែមការព្យាបាលនៅមន្ទីរពេទ្យ និងការពារការឆ្លងរាលដាលទៅដល់សហគមន៍។

សម្រាប់ព័ត៌មានចុងក្រោយស្តីអំពីកូវិដ-១៩ COVID-19 ដែលជាព័ត៌មានលំអិតស្តីអំពីអ្វីៗ ដែលទីក្រុងឡុងប៊ិចកំពុងតែធ្វើ ដើម្បីរក្សាសុវត្ថិភាពជូនដល់ប្រជាជនរបស់ខ្លួន សូមចូលមើលវែបសាយគេហទំព័រ [longbeach.gov/COVID19] និងតាមដានលើហ្វេសប៊ុក @LongBeachCity ធ្វីតធ័រ Twitter និងអ៊ិនស្ទេក្រាម Instagram ។

សម្រាប់ព័ត៌មានបន្ថែម រូបភាព វីឌីអូ និងសេចក្តីប្រកាសដំណឹងផ្សេងៗ អំពីអ្វីៗ ដែលកំពុងកើតឡើងនៅក្រុងឡុងប៊ិច សូមតាមដានពួកយើង។